# ភាពផឹតផុលនិងការបោកបញ្ឆោតនៃអំពើបាប

## The Masking and Deceit of Sin

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

អំពើបាប តែងតែផ្តល់ផលអវិជ្ជមាន ទោះជាដឹងយ៉ាងនេះហើយក៏ដោយ ក៏មនុស្សនៅតែចាញ់បញ្ឆោតបាបដោយរុលត្រុកដើរតាមវាដំដែល។ តើមនុស្សមានភាពល្ងង់ខ្លៅប៉ុណ្ណា ក្នុងការដែលដឹងហើយ តែនៅតែប្រព្រឹត្តវាទៀតនោះ។ យើងតែងតែបោកបញ្ឆោតខ្លួនឯង ដោយជឿថា បាបនាំផលវិជ្ជមានដល់យើង ដូចជា ភាពរីករាយជាដើម....។ វាជាការបោកប្រាស់ ពីព្រោះវាសន្យាថា នឹងធ្វើឱ្យយើងកាន់តែសប្បាយ... តែការពិតគឺធ្វើឱ្យយើងកើតទុក្ខទៅវិញទេ។ ជាញឹកញយ មនុស្សជឿលើការបោកប្រាស់ លុះក្រោយមកក៏ធ្លាក់ចុះទៅក្នុងស្ថានភាពមួយដ៏អាក្រក់។ លោកអ័ដាមនិងនាងអេវ៉ា ជាឧទាហរណ៍ស្រាប់ ទោះបាបមានទ្រង់ទ្រាយធំទូលាយនៅក្នុងខ្លួនរបស់មនុស្សយើងក៏ដោយ ក៏មនុស្សយើងនៅតែគិតថាខ្លួនឯងល្អ ដោយមើលមិនឃើញអំពើបាបរបស់ខ្លួនឯងឡើយ។ ហេតុមួយដែលនាំឱ្យមនុស្សមើលមិនឃើញអំពើបាបរបស់ខ្លួន គឺដោយសាមនុស្សគិតថា អំពើរបស់ពួកគេនឹងមានលទ្ធផលល្អ។ ដូចជានៅក្នុងសួនច្បារអេដែន អ័ដាមនិងនាងអេវ៉ា បានគិតថានឹងមានលទ្ធផលល្អក្រោយពេលមិនស្តាប់បង្គាប់ព្រះអង្គ។ ដើមឈើដែលព្រះហាមមិនឱ្យបរិភោគ តែចំពោះអេវ៉ាបែរជាមើលឃើញថា ជាដើមឈើ "ល្អ" វិញ។ លោកុប្បត្តិ ៣:៦ បានចែងថា «កាលស្ត្រីបានឃើញថា ផ្លែឈើនោះបរិភោគបានក៏ជាទីគាប់ដល់ភ្នែក ហើយជាដើមដែលល្អមគួរនឹងចង់បាន ដើម្បីឱ្យបានប្រាជ្ញា»។ សព្វថ្ងៃនេះមនុស្សក៏គិតដូចនោះដែរ មនុស្សមើលទៅអំពើបាបហាក់ដូចជា គួរឱ្យចាប់អារម្មណ៍ និងមើលទៅហាក់ដូចជារឿងត្រឹមត្រូវ។ មនុស្សធ្លាប់គិតថា «បើខ្ញុំលួចគេក៏មិនអី ដ្បិតអីខ្ញុំក្រ»។ «ពេលដែលខ្ញុំសំឡាប់អ្នកណាម្នាក់ គឺខ្ញុំកំពុងជួយពិភពលោក ពីព្រោះខ្ញុំបានដកមនុស្សអាក្រក់ចេញពីផែនដីនេះ»។ «ពេលខ្ញុំប្រព្រឹត្តសេចក្តីកំផិតនោះបញ្ជាក់ថាខ្ញុំស្រឡាញ់គេ»។ «ការនិយាយកុហកដោយមិនព្រមទទួលស្គាល់នូវកំហុសរបស់ខ្លួន វាជារឿងដ៏ត្រឹមត្រូវ ពីព្រោះវាធ្វើឱ្យខ្ញុំមិនមានបញ្ហាអ្វីទាំងអស់»។ មនុស្សមានវិធីជាច្រើនយ៉ាងក្នុងការបកស្រាយពីអំពើបាបរបស់ខ្លួនគេ ថា រឿងត្រឹមត្រូវ។

ទំនុក. ១៩:១២, ៩០:៨, ៣៦:១-២, ម៉ាថាយ ៧:៣ ខព្រះគម្ពីរទាំងនេះ បានបង្ហាញថា មនុស្សមិនអាចមើលឃើញនូវបាបរបស់ខ្លួនឡើយ។ នៅក្នុងព្រះគម្ពីរលូកា ១៨:៩-១៤ អ្នកផារ៉ាស៊ីម្នាក់បានប្រៀបធៀបខ្លួនរបស់គាត់ទៅនឹងអ្នកឯទៀត ដូច្នេះធ្វើឱ្យគាត់មើលឃើញខ្លួនគាត់មានភាពសុចរិតជាងអ្នកឯទៀត។ តែចំពោះយើងវិញ យើងមិនគួរប្រៀបធៀបខ្លួនរបស់យើងជាមួយអ្នកឯទៀតទេ តែគួរប្រៀបធៀបខ្លួនយើងនឹងព្រះអង្គវិញ ដែលការនោះនឹងនាំឱ្យយើងរហ័សមើលឃើញនូវអំពើបាបរបស់ខ្លួន(ឧ.អេសាយ, ២សាំយូអែល ១២:១-១៥)ជាង។

សូម្បីតែការងារដែលយើងធ្វើថ្វាយព្រះ ក៏អាចបំផ្លាញទៅជាមួយអំពើបាបដែរ។ ការអធិស្ឋានវែងៗនៅចំពោះមុខមនុស្សដទៃ ដើម្បីឱ្យគេគិតថាយើងជាមនុស្សបរិសុទ្ធ នោះអាក្រក់ចំពោះព្រះហើយ (ម៉ាថាយ ៦:៥-៧)។

### សំនួរ

តើបាបបោកបញ្ឆោតយើងយ៉ាងម៉េច?

# ទំហំបាបរបស់សង្គម The Social Dimension of Sin

កន្លងមក ពេលយើងនិយាយពីអំពើបាប យើងលើកយកអំពើបាបរបស់បុគ្គលមកនិយាយ។ តែព្រះគម្ពីរក៏បានលើកយកអំពើបាបរបស់ក្រុមមនុស្ស ឬជួនកាលនិយាយពីបាបរបស់ជាតិសាសន៍តែម្តង។ នៅក្នុងគ្រាសញ្ញាចាស់ ពេលដែលព្រះអង្គប្រកាសកាត់ទោសអំពើបាប ទ្រង់មិនត្រឹមតែលើកឡើងពីបាបរបស់បុគ្គលនោះទេ តែព្រះអង្គមានបន្ទូលប្រឆាំងនឹង

បាបរបស់សង្គមទាំងមូលឬរបស់ជាតិសាសន៍នោះតែម្តង ជាពិសេសគឺបាបរបស់សាសន៍អ៊ីស្រាអែល។ ព្រះអម្ចាស់បានជំនុំជំរះសង្គមផ្សេងៗពីព្រោះ គេមានភាពអយុត្តិធម៌ និងការគាបសង្កត់,..។ល។ វាពិបាកណាស់ ក្នុងការវិភាគឱ្យឃើញបាបនៅក្នុងសង្គមរបស់យើងជាពិសេស ប្រសិនបើយើងមានចំនែកក្នុងបាបនោះដែរ។ បាបដែលយើងប្រព្រឹត្តក្នុងសង្គម វាមិនសូវមានលក្ខណៈដោយផ្ទាល់ប៉ុន្មានទេ ភាគច្រើនមានលក្ខណៈដោយប្រយោល។ ឧទាហរណ៍ ប្រហែលជាយើងមិនបានគាបសង្កត់មនុស្សក្នុងសង្គមដោយផ្ទាល់ ប៉ុន្តែយើងបានគាបសង្កត់ពួកគេរួចទៅហើយ ដោយកេងចំណេញលើកំលាំងពលកម្មពួកគេ។ ដូចដែលយើងបានដឹងរួចមកហើយថា បាបមិនមែនគ្រាន់តែការអាក្រក់ដែលយើងមិនគួរធ្វើនោះទេ តែការល្អដែលយើងគួរធ្វើ តែបែរជាមិនធ្វើនោះក៏រាប់ជាបាបដែរ។ ពាក្យនេះក៏យើងអាចយកមកអនុវត្តន៍ក្នុងសង្គមបានដែរ ពេលណាឃើញថាសង្គមធ្លាក់ចុះ។ ឧទាហរណ៍. ដូចជាមានការជិះជាន់លើកំលាំងពលកម្មជាដើម តែសង្គមទាំងមូលនៅតែធ្វើដូចជាមិនដឹងមិនឮអ្វីទាំងអស់ នៅតែមិនព្រមខ្វល់អ្វីទាំងអស់ មិនព្រមងើបឡើងតវ៉ាប្រឆាំងទេ នៅតែស្ងៀម នោះមានន័យថាសង្គមទាំងមូលមានបាបហើយ (អេសាយ ១:១៧-២១ អេម៉ុស ៥:១១-១២ យេរេមា ៥:២៦-២៨)។

# *ការទប់ស្កាត់អំពើបាប* The Restraint of Sin

ពេលដែលយើងសង្កេតមើលនៅក្នុងប្រវត្តិសាស្ត្រ និងការពិពណ៌នារបស់ព្រះគម្ពីរ យើងក៏បានមើលឃើញថា មនុស្សបានធ្វើបាបយ៉ាងច្រើន ពេលនោះយើងឆ្ងល់ថា អញ្ចឹងបើគ្រប់គ្នាសុទ្ធតែស្រឡាញ់បាបនិងចូលចិត្តបាបខ្លាំងយ៉ាងនេះតើជីវិតនៅលើផែនដីនេះនឹងទៅជាយ៉ាងណាទៅ? យើងក៏បានដឹងហើយថា ការព្យាយាមផ្លាស់ប្រែសង្គមឱ្យបានល្អតាមរយៈសិក្សាធិការ និងការប្រកាសឱ្យមនុស្សរស់នៅប្រកបដោយសីលធម៌ ប្រព្រឹត្តតែអំពើល្អ មិនបានជួយដោះស្រាយ ក៏នឹងមិនអាចដោះស្រាយ នូវបញ្ហាធំបំផុតបានដែរ ព្រោះជានិស្ស័យបាប។

យើងក៏បានឃើញថា មនុស្សមិនមែនសុទ្ធតែតែអាក្រក់នោះទេ សូម្បីតែអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ ក៏អាចធ្វើការល្អបានដែរ គេចេះស្រឡាញ់អ្នកដទៃទៀត គេចេះរស់នៅធ្វើជាអ្នកជិតខាងយ៉ាងល្អ....។ល។ តាមរយៈទង្វើបែបនេះមានសំនួរជាច្រើនក៏បានលើកឡើង៖

**ក.** ការពណ៌នាពីមនុស្សជាតិរបស់ព្រះគម្ពីរ ពិតជាត្រឹមត្រូវមែនទេ?

**ខ.** តើមូលហេតុអ្វី បានជា *សូម្បីអ្នកដែលមិនមែនជាគ្រីស្ទបរិស័ទ* ក៏ អាចធ្វើការល្អបានដែរ?

**គ.** តើព្រះអង្គបានដាក់ឧបករណ៍អ្វីខ្លះ ដើម្បីទប់ស្កាត់ការអាក្រក់ដើម្បីឱ្យការល្អកើតឡើងបាន?

ព្រះគម្ពីរមានចំលើយសំរាប់សំនួរទាំងអស់នេះ ៖

**ឃ.** ត្រឹមត្រូវ ព្រះគម្ពីរពិតជាពណ៌នាយ៉ាងត្រឹមត្រូវពីមនុស្សមែន ហើយក៏មានការពណ៌នា អំពីការល្អដែលមានក្នុងមនុស្សដែរ ជាមួយគ្នាព្រះគម្ពីរក៏បានចែងថាមិនមានអ្នកណាម្នាក់អាចឈោងដល់ខ្នាតរង្វាស់របស់ព្រះឡើយ។ ឧទាហរណ៍មួយយ៉ាងច្បាស់គឺមានក្នុងព្រះគម្ពីរម៉ាថាយ ៥:៤៣-៤៨។ ត្រង់នេះព្រះយេស៊ូវបានមានបន្ទូលយ៉ាងច្បាស់ថា សូម្បីតែពួកអ្នកយកពន្ធដែលត្រូវបានគេរាប់ថាជាប្រភេទមនុស្សអាក្រក់ក្នុងចំណោមពួកមានបាប ក៏ចេះស្រឡាញ់ដល់អស់អ្នកដែលស្រឡាញ់ខ្លួនដែរ មានន័យថាពួកគេមានសមត្ថភាពក្នុងការសំដែងចេញនូវក្តីស្រឡាញ់។ ព្រះយេស៊ូវបានមានបន្ទូលបន្តទៀតថា ការដែលស្រឡាញ់ដល់អស់អ្នកណាដែលស្រឡាញ់ខ្លួន នោះមិនមានអ្វីប្លែកទេ ហើយវាក៏ជាសកម្មភាពមួយដែលខ្វះមិនដល់ខ្នាតគំរូរបស់ព្រះអង្គដែរ។

**ង.** ទោះជាមនុស្សបានបែកចេញពីព្រះអង្គ ហើយរស់នៅក្នុងភាពងងឹតហើយក្តី ក៏មិនមានន័យថា លក្ខណៈរបស់ព្រះបានបាត់បង់អស់រលីងពីខ្លួនមនុស្សនោះដែរ។ យើងឃើញថា ក្រោយការធ្លាក់ចុះ ភាពដូចជារូបអង្គទ្រង់នៅតែមានក្នុងមនុស្សដដែល គ្រាន់តែភាពនេះត្រូវបានប្តូរទ្រង់ទ្រាយ និងខូចបង់។ វាមិនមែនបាត់បង់ទាំងស្រុងនោះទេ មនុស្សទាំងអស់នៅមានសមត្ថភាពក្នុង ការធ្វើការល្អបានខ្លះ ដូចជា ចេះជួយដល់សង្គម មានអំណោយទានក្នុងវិស័យសិល្បៈ ចេះមាន

គំនិតច្នៃប្រឌិត ចេះធ្វើការសិក្សាស្រាវជ្រាវខាងវិទ្យាសាស្ត្រ ការជឿនលឿនខាងបច្ចេកវិជ្ជា ចេះមានចិត្តខ្វល់ខ្វាយចំពោះភាពអយុត្តិធម៌......។ល។ " ***ដូចជារូបអង្គទ្រង់*** " នៅតែមានក្នុងមនុស្សបាប ហើយនេះជាមូលហេតុដែលយើងអាចនិយាយថា មនុស្សនៅមានមនសិការដែលព្រះអង្គប្រទានអោយដដែល។ ដូចជាព្រះបន្ទូល រ៉ូម ២ មានបន្ទូលថា ទោះជាពួកសាសន៍ដទៃដែលមិនមានព្រះបន្ទូលបើកសំដែងក៏ដោយ ក៏ពួកគេមានក្រិត្យវិន័យ របស់ព្រះបានកត់ទុកក្នុងចិត្ត របស់ពួកគេរួចទៅហើយ (រ៉ូម ២:១៥)។

សំនួរដ៏សំខាន់មួយសួរថា តើអ្នកណាជាអ្នកកត់ទុកនូវក្រិត្យច្បាប់នោះក្នុងចិត្តរបស់ពួកគេ? គឺវាជាអំណោយទានដែលព្រះអង្គប្រទានឱ្យដល់គ្រប់មនុស្សទាំងអស់។ អំណោយទាននេះមកពីព្រះអង្គ មិនមែនបានមកពីការងារដែលមនុស្សខំអភិវឌ្ឍន៍ខ្លួនឯងនោះទេ។ ដូច្នេះហើយយើងក៏មិនអាចនឹងអួតខ្លួន ចំពោះអំណោយទាននេះបានដែរ។ នៅក្នុងប្រវត្តិសាស្ត្រពួកជំនុំ ពេលខ្លះគេហៅអំណោយទានដែលព្រះអង្គប្រទានឱ្យពួកគេតាមរយៈព្រះគុណទ្រង់ ថា ***ព្រះគុណធម្មតា (ព្រះគុណសំរាប់មនុស្សទាំងអស់***) (*common grace*) ។

នេះជាគោលលទ្ធិមួយមានសារៈសំខាន់ណាស់ ដែលត្រូវបង្រៀនដល់គ្រីស្ទបរិស័ទ ឱ្យចេះមានភាពកតញ្ញូចំពោះលោកិយ (មិនមែនគ្រីស្ទាន) ដែលបានជួយឱ្យមានផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេស, បង្កើតឱសថ រដ្ឋាភិបាល សិល្បៈ ដូរតន្ត្រី...។ល។ ហើយចំពោះគ្រីស្ទានក៏អាច និងក៏ត្រូវតែចូលរួមចំនែកក្នុងការនេះផងដែរ។

ច. ព្រះគម្ពីរបង្រៀនថា ព្រះទ្រង់ជាអ្នករើសតាំងមនុស្សឡើងឱ្យឈរក្នុងតួនាទីផ្សេងៗដូចជា ទ្រង់តាំងឱ្យមានអាជ្ញាធរក្នុងជួររដ្ឋាភិបាលតាមលំដាប់ថ្នាក់ដើម្បីសំដែងចេញនូវសេចក្ដីសុចរិតនិងទប់ស្កាត់ បង្ក្រាបអំពើបាបក្នុងសង្គម។ ពួកគេជាអ្នកមានអំណាចក្នុងការដាក់ទណ្ឌកម្មដល់ពួកអ្នកដែលប្រព្រឹត្តខុសហើយ ក៏ជាអ្នកដែលការពារភាពស្មើចសរសើរដល់ពួកអ្នកដែលរស់នៅដោយត្រឹមត្រូវ (រ៉ូម១៣:១-៦, ១ធីម៉ូថេ ២:១-៤, ១ពេត្រុស ២:១៣-១៤)។

# *សេចក្ដីសន្និដ្ឋាន* Conclusion

តាមការសិក្សាពីគោលទ្ធិអំពើបាបខាងលើ យើងអាចសន្និដ្ឋានបានថា បញ្ហាចំបងដែលកើតមានក្នុងមនុស្សជាតិ គឺជា "បាប"។ អំពើបាបគឺជាភាពអវិចារណញ្ញាណ។ នេះមានន័យថា មិនដែលមានការល្អណាមួយកើតចេញពីអំពើបាបឡើយ តែវាបង្កតែភាពស្មុគស្មាញ ដែលនាំឱ្យមានការអាក្រក់ និងបញ្ហាគ្រប់យ៉ាង។ ទោះជាដឹងដូច្នោះហើយក៏ដោយ ក៏មនុស្សនៅតែរុលតត្រុកក្នុងអំពើបាបនោះដដែល ហើយថែមទាំងដឹងច្បាស់ថា ហឺ! វាមិនអីទេ! មានអីធ្ងន់ធ្ងរ បើប៉ុណ្ណឹងហ្នឹង!។

និស្ស័យបាបដែលព្រះគម្ពីរបានបង្រៀន មានសភាពស៊ីជំរៅជាងការយល់ឃើញរបស់មនុស្សទៅទៀត។ បាបមិនគ្រាន់តែជាសកម្មភាពប៉ុណ្ណោះទេ តែវាទាក់ទងនិងគំនិតយោបល់ វាមិនគ្រាន់តែជាអ្វីដែលយើងធ្វើ តែទោះជាយើងនៅស្ងៀមក៏ជាបាបដែរ មិនត្រឹមតែរំលងច្បាប់របស់មនុស្សទេ តែវាជាការប្រឆាំងនឹងបុគ្គលភាពនៃព្រះជាម្ចាស់ទៀតផង។ មនុស្សមិនមែនមានសីលធម៌អព្យាក្រិតទេ មិនមានសមត្ថភាពក្នុងការជ្រើសរើសធ្វើល្អ ឬអាក្រក់ដោយខ្លួនឯងដែរ ប៉ុន្តែតែងតែមានទំនោរទៅខាងបាបវិញ។ ចិត្តនិងគំនិតរបស់មនុស្សបើមិនមានអន្តរាគមន៍ពីអំណាចនៃព្រះវិញ្ញាណបរិសុទ្ធទេ នោះមនុស្សមិនមានលទ្ធិភាពសោះក្នុងការចុះចូលចំពោះច្បាប់ ឬព្រះបន្ទូលរបស់ព្រះអង្គ និងក៏គ្មានលទ្ធភាពសោះក្នុងការឈោងចាប់ខ្នាតគំរូរបស់ព្រះ។

ដូច្នេះការសិក្សាពីគោលទ្ធិអំពើបាបឱ្យបានច្បាស់លាស់ ពិតជាមានសារៈសំខាន់ណាស់ ព្រោះវាធ្វើឱ្យយើងអាចមើលឃើញអំពើបាបនៅក្នុងខ្លួនយើង និងបាបរបស់សង្គមជាតិ ដើម្បីនាំយើងឱ្យចេះដាក់ទំនុកចិត្តប្រកបដោយការអរព្រះគុណដល់ព្រះយេស៊ូវគ្រីស្ទ ដែលទ្រង់បានប្រោសលោះយើង ដោយប្រគល់អង្គទ្រង់ជំនួសយើង ហើយការនេះក៏ជួយលើកទឹកចិត្តយើង ឱ្យយើងចេះប្រែចិត្តចេញពី អំពើទាំងអស់ ដែលទ្រង់មិនសព្វព្រះទ័យនោះវិញ។